# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៧. សរណន

# សារាចរណែនាំ

## ស្តីពី

## ការអនុវត្តគំរោងរបស់អង្គការពលកម្មអន្តរជាតិ ដើម្បីធ្វើឱ្យប្រសើរឡើង ដល់រោងចក្រកម្ពុជា ក្នុងវិស័យវាយនភ័ណ្ឌ និងសំលៀកបំពាក់

ក្នុងស្មារតីលើកកំពស់ និងការពារសិទ្ធិកម្មករ និងនិយោជិតក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យកាន់តែមានលក្ខណៈល្អប្រសើរស្របតាមស្តង់ដាររបស់អង្គការពលកម្មអន្តរជាតិ (ILO) រាជរដ្ឋាភិបាលកម្ពុជាដាក់ចេញនូវសេចក្តីណែនាំ ដូចខាងក្រោម :

**ទី១:** អនុវត្តគោលនយោបាយឯកតោភាគីជាមូលដ្ឋានរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយផ្សារភ្ជាប់លក្ខខ័ណ្ឌការងារក្នុងវិស័យវាយនភ័ណ្ឌ និងសំលៀកបំពាក់នៅកម្ពុជា ជាមួយពាណិជ្ជកម្មអន្តរជាតិ ។

**ទី២:** អនុវត្តគំរោងដែលរៀបចំថ្មីរបស់អង្គការពលកម្មអន្តរជាតិដើម្បីធ្វើឱ្យប្រសើរឡើងដល់រោងចក្រកម្ពុជា ក្នុងគោលបំណងបន្តលើកកំពស់លក្ខខ័ណ្ឌការងារក្នុងវិស័យវាយនភ័ណ្ឌ និងសំលៀកបំពាក់ រួមបញ្ចូលទាំងការគោរពស្តង់ដារការងារដែលទទួលស្គាល់ជាអន្តរជាតិ តាមរយៈការអនុវត្តច្បាប់ស្តីពីការងាររបស់ព្រះរាជាណាចក្រកម្ពុជា។ ក្នុងការអនុវត្តគំរោងនេះ កម្ពុជានឹងធានាថា ច្បាប់ស្តីពីការងារ និងបទដ្ឋានផ្សេងៗ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ហើយបង្កើតឱ្យមាននូវបរិយាកាសការងារប្រកបដោយផលិតភាព និងគុណភាពខ្ពស់ ព្រមទាំងជំរុញឱ្យមានតម្លាភាពក្នុងការអនុវត្តច្បាប់ស្តីពីការងារ ដើម្បីឱ្យមានភាពរលូនក្នុងការពង្រឹងប្រសិទ្ធភាពច្បាប់ និងបទដ្ឋានការងារដែលមានស្រាប់ និងលើកស្ទួយសិទ្ធិការងារទូទៅ ដូចមានចែងនៅក្នុងច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា ។

**ទី៣:** គ្រប់រោងចក្រវាយនភ័ណ្ឌ និងសំលៀកបំពាក់ ព្រមទាំងអ្នកម៉ៅការផលិតបន្ត ត្រូវចុះបញ្ជីនៅការិយាល័យគំរោងរបស់អង្គការពលកម្មអន្តរជាតិដើម្បីធ្វើឱ្យប្រសើរឡើងដល់រោងចក្រកម្ពុជា ហើយត្រូវរួមគ្នាគោរពច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទទួលបានសិទ្ធិស្របច្បាប់សំរាប់ការនាំចេញ ។

**ទី៤:** រោងចក្រវាយនភ័ណ្ឌ និងសំលៀកបំពាក់ទាំងឡាយ ដែលបានចុះបញ្ជីនៅការិយាល័យរបស់អង្គការពលកម្មអន្តរជាតិដើម្បីធ្វើឱ្យប្រសើរឡើងដល់រោងចក្រកម្ពុជា មានសិទ្ធិស្នើសុំវិញ្ញាបនប័ត្រប្រភពដើមទំនិញ និងឯកសារនាំចេញផ្សេងៗពីក្រសួងពាណិជ្ជកម្ម ក្រោយពីបានចុះបញ្ជីប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ។

**ទី៥:** ក្នុងករណីរោងចក្រវាយនភ័ណ្ឌ និងសំលៀកបំពាក់ទាំងឡាយ ដែលមិនបានចុះបញ្ជីជាមួយគំរោងរបស់អង្គការពលកម្មអន្តរជាតិដើម្បីធ្វើឱ្យប្រសើរឡើងដល់រោងចក្រកម្ពុជា នឹងត្រូវលុបចេញពីបញ្ជីប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ហើយនឹងមិនអនុញ្ញាតឱ្យធ្វើការនាំចេញឡើយ ។

**ទី៦:** រោងចក្រវាយនភ័ណ្ឌ និងសំលៀកបំពាក់ទាំងឡាយ ដែលមិនព្រមអនុវត្តតាមច្បាប់ស្តីពីការងារ និងបទដ្ឋានគតិយុត្តិជាធរមាន នឹងត្រូវទទួលការពិន័យរដ្ឋបាលពីក្រសួងពាណិជ្ជកម្ម ជាបួនតំណាក់កាលដូចខាងក្រោម :

១- ត្រូវទទួលលិខិតព្រមានពីក្រសួងពាណិជ្ជកម្ម នៅពេលដែលពិនិត្យរបាយការណ៍ឃើញថា មានការរំលោភច្បាប់ស្តីពីការងារ និងបទដ្ឋានគតិយុត្តិធ្ងន់ធ្ងរ ដោយមានការបញ្ជាក់ពីក្រុមឃ្លាំមើលគំរោងរបស់អង្គការពលកម្មអន្តរជាតិ ដើម្បីធ្វើឱ្យប្រសើរឡើងដល់រោងចក្រកម្ពុជា ដែលស្របនឹងរបាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

២- ហាមនាំចេញផលិតផលវាយនភ័ណ្ឌ និងសំលៀកបំពាក់ ក្នុងរយៈពេល ១សប្តាហ៍ ចំពោះរោងចក្រទាំងឡាយណាដែលមានកំហុស ហើយពុំបានកែប្រែក្នុងអំឡុងពេល ១សប្តាហ៍ បន្ទាប់ពីបានទទួលលិខិតព្រមានរួច ។

៣- ហាមនាំចេញផលិតផលវាយនភ័ណ្ឌ និងសំលៀកបំពាក់រយៈពេល ៣ខែ ចំពោះរោងចក្រទាំងឡាយណាដែលមានកំហុស ហើយពុំបានកែប្រែក្នុងអំឡុងពេល ២សប្តាហ៍ បន្ទាប់ពីបានទទួលលិខិតព្រមានរួច ។

៤- ហាមនាំចេញផលិតផលវាយនភ័ណ្ឌ និងសំលៀកបំពាក់ជាស្ថាពរ ចំពោះរោងចក្រទាំងឡាយណាដែលមានកំហុស ហើយពុំបានកែប្រែក្នុងអំឡុងពេល ៣ខែ បន្ទាប់ពីបានទទួលលិខិតព្រមានរួច ។

**ទី៧:** ក្នុងករណីដែលមានការហាមឃាត់ ចំពោះរោងចក្រដែលមានកំហុសដូចបានរៀបរាប់ខាងលើ គ្រប់ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចនៅតាមច្រកទ្វារព្រំដែនទាំងអស់ ត្រូវសហការគ្នាឱ្យបានល្អជាមួយក្រសួងពាណិជ្ជកម្ម ក្នុងការអនុវត្តបំរាមនេះ ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់ខេត្ត-ក្រុង ត្រូវចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>ចំលងជូន</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- គ្រប់ស្ថានឯកអគ្គរដ្ឋទូតកម្ពុជា ប្រចាំនៅបរទេស
- គ្រប់ស្ថានទូតបរទេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
  "ដើម្បីជូនជ្រាប"
- ការិយាល័យធ្វើឱ្យប្រសើរឡើងដល់រោងចក្រកម្ពុជារបស់អង្គការ ILO
- សមាគមរោងចក្រកាត់ដេរកម្ពុជា
- ដូចមាត្រាទី៣
  "ដើម្បីអនុវត្ត"
- រាជកិច្ច ទូរទស្សន៍ និងវិទ្យុជាតិ
  "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ